# ការសិក្សាពីស្ថានភាពទូទៅនៃប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាបច្ចុប្បន្ន នៅកម្ពុជា

## An Overview of Cambodian Higher Education

ដោយ លោក *រុន សម្បត្តិ* កញ្ញា *ហាក់ ស៊ីភិរ័តន៍* និង កញ្ញា *ហេង ឈុនអឿន*
by *Run Sambath, Hak Siphirath, Heng Chhun Oeurn*

*Investment in higher education is a long-term investment in both the national economy as well as society and culture. Cambodia's changing political economy makes education an important component determining the future direction of its society. There are many difficulties the education sector will face to grow and improve, and this growth should be accomplished in concert with the growth and development of other sectors.*

*Following Cambodia's change from a centrally-planned economy to a market economy in the early 1990's, strengthening the education sector has been considered a key effort in stabilizing society and economic growth (Ahrens and Kemmerer 2002). Education produces qualified human resources which are highly needed in a democratic society (Mayer 1995). Cambodia's educational system is in a transitional phase, due to rapid societal change. In response to the demand of graduate students, in 1997 the state allowed private institutions to compete with state schools (of which examples are Norton Institute of Management, and the Institute of Technology and Management).*

*In the school year 1999-2000, a total of 14,986 students registered in private institutions with only 6,751 in state institutions. State and private lecturers total 1,135. Most of the lecturers in private schools have Master's or Doctoral degrees (MOEYS 2002). However, Mayor (1995) has noted that sharp increases in student numbers does not guarantee an increase in the quality of students. There are advantages and disadvantages to these rising numbers, which will need to be addressed by the government.*

*More students also means more employment opportunities for teachers - MA and Ph.D graduates, and gives them an opportunity to contribute their skills. This will also contribute to the constructive growth of Cambodian higher education.*

### ទស្សនៈទូទៅលើប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា

ឧត្តមសិក្សាគឺជាការបណ្ដាក់ទុនជាតិរយៈពេលយូរមួយ សម្រាប់លើកកម្ពស់ការប្រណាំងប្រជែងសេដ្ឋកិច្ច ការអភិវឌ្ឍវប្បធម៌ និងរចនាសម្ព័ន្ធសង្គម ។ បើមានការផ្លាស់ប្ដូរឥទ្ធិពលនៃនយោបាយសេដ្ឋកិច្ចក្នុងប្រទេស វានាំឲ្យតម្រូវការទីផ្សារប្រែប្រួលទៅតាមហ្នឹងដែរ ជាពិសេសទីផ្សារនៃប្រព័ន្ធអប់រំ គឺជាគន្លឹះដ៏សំខាន់សម្រាប់វែកផ្លូវសង្គមមនុស្ស ឬ ប្រទេសឲ្យឈានទៅដល់គោលដៅរីកចម្រើនបានល្អ ហើយមានរយៈពេលយូរ ។ ប៉ុន្តែក្នុងជំហានមួយៗ នៃការអភិវឌ្ឍទាំងនោះវាតែងតែជួបប្រទះនូវការលំបាកយ៉ាងខ្លាំង និងធ្វើដំណើរដោយ សន្សឹមៗក្នុងរយៈពេលយូរអង្វែង ព្រោះថាការអប់រំវាត្រូវការរៀបចំតាំងពីកម្រិតក្រោមបំផុតរហូតដល់កម្រិតខ្ពស់ដែលជាថ្នាក់ឧត្តមសិក្សា ឬ កម្រិតលើនេះទៀត ដោយមិនសំដៅតែចំពោះសង្គមថ្នាក់ទាប ឬ សង្គមថ្នាក់ខ្ពស់នោះទេ ហើយប្រសិនបើគ្រប់ចំណុចមិនដើរទន្ទឹមគ្នា នោះដំណើរនៃការអភិវឌ្ឍក៏មិនអាចឈានទៅមុខបានដែរ។

ផ្អែកលើបញ្ហាខាងលើនេះ កម្ពុជាគឺជាឧទាហរណ៍មួយ អាចឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការផ្លាស់ប្ដូរសេដ្ឋកិច្ចទីផ្សារសេរីនាដើមទស_វត្សឆ្នាំ ៩០ ដែលវាជំរុញឲ្យបង្កើតការបណ្ដុះបណ្ដាលធនធានមនុស្សផ្អែកខាងអប់រំជាកត្តាចំបង ព្រោះនៅពេលដែលទីផ្សារមានតម្រូវការកាន់តែច្រើន សង្គមត្រូវការចាំបាច់នូវបរិមាណប្រជាពលរដ្ឋដែលមានចំណេះដឹង មានគុណភាពក្នុងវិស័យឧត្តមសិក្សា (Kemmerer 2002) ហើយអ្នកទាំងនោះអាចមានសមត្ថភាពទៅបង្គ្រប់នឹងតម្រូវការគ្រប់ជ្រុងទាំងអស់នៃសង្គមទាំងមូល ។ ដូចគ្នានេះ សង្គមដែលមានលទ្ធិប្រជាធិបតេយ្យ ក៏ត្រូវទាមទារធនធានមនុស្សច្រើនសម្រាប់បំពេញសេដ្ឋកិច្ចទីផ្សារកើនឡើងដែរ ហើយវាជាកូនសោសម្រាប់ចាក់ឲ្យមានតម្រូវការបរិមាណ និង គុណភាពខាងប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សា (Mayor 1995) ។ ដោយឡែកវិស័យអប់រំនៅកម្ពុជាក៏កំពុងតែត្រូវបានស្ថិតនៅលើលក្ខខ័ណ្ឌដែលបានរៀបរាប់ខាងលើនេះដែរ ទាំងការផ្លាស់ប្ដូរសេដ្ឋកិច្ចនិងនយោ_បាយសង្គម ។ ដើម្បីឆ្លើយតបនឹងតម្រូវការទាំងនេះ កម្ពុជាបានបើកចំហឲ្យមានការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនជាច្រើននៅឆ្នាំ

១៩៩៧ ដូចជាគ្រឹះស្ថានឧត្តមសិក្សានរ័តុន វិទ្យាស្ថានអន្តរជាតិនៃកម្ពុជា វិទ្យាស្ថានបច្ចេកវិទ្យា និង គ្រប់គ្រងជាដើម (ក.អ.យ.ក. ឆ្នាំ ២០០០) ដើម្បីជាលទ្ធភាពអាចទទួលយកនិស្សិតឲ្យចុះឈ្មោះចូលរៀនបាននៅក្នុងកម្រិតឧត្តមសិក្សាកាន់តែច្រើន ។ នៅឆ្នាំ ១៩៩៩-២០០០ ចំនួននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាឯកជនមានរហូតទៅដល់ ១៤.៩៨៦ នាក់ ចំណែកចំនួននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋគឺមានតែ ៦.៥៧១ នាក់ ប៉ុណ្ណោះ ឯគ្រូមានរហូតដល់ ១.១៣៥ នាក់ ហើយគ្រូភាគច្រើននៃគ្រឹះស្ថានឧត្តមសិក្សាឯកជនមានកម្រិតអនុបណ្ឌិត និង បណ្ឌិត (ក.អ.យ.ក. ២០០០) ។ ការកើតឡើងនេះវាមិនមែនទទួលបានលទ្ធផលវិជ្ជមានទាំងអស់ទេ (Mayor 1995) គោលការណ៍នេះ វាចំណេញបានបរិមាណនៃធនធានមនុស្សក៏ពិតមែន ប៉ុន្តែបើយើងធ្វើការសិក្សាឲ្យស៊ីជម្រៅទៅឃើញថា វាអាចមានផលជាវិជ្ជមាន និង អវិជ្ជមានខ្លះ។ ដែលរដ្ឋាភិបាលជាអ្នកមានតួនាទីទទួលបន្ទុកដោះស្រាយនាពេលអនាគត ។ ក៏ប៉ុន្តែការកើតឡើងនៃគ្រឹះស្ថានឯកជន វាហាក់ដូចជាទីផ្សារមួយសម្រាប់ឲ្យអ្នកដែលទៅរៀនយកថ្នាក់អនុបណ្ឌិត និង បណ្ឌិតនៅឯបរទេសមានឱកាសផ្សព្វផ្សាយ ឬ បង្រៀននូវចំណេះដឹងដែលខ្លួនមានដល់និស្សិតជំនាន់ក្រោយ នេះគឺជាធនធានមួយដ៏សំខាន់សម្រាប់អភិវឌ្ឍន៍ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងស្រុកខ្មែរសម្រាប់ថ្ងៃខាងមុខទៀត ។

មូលហេតុនៃពេលវេលាមិនអាចអនុគ្រោះដល់ការស្រាវជ្រាវឲ្យមានលក្ខណៈទូទៅផ្តោតលើគ្រឹះស្ថានទាំងពីរ គឺរដ្ឋ និង ឯកជនបានយើងខ្ញុំគ្រាន់តែសូមធ្វើការលើកជាគំនិតខ្លះ។ ដើម្បីស្ទាបស្ទង់ពីគ្រឹះស្ថានឧត្តមសិក្សារដ្ឋក្នុងអត្ថបទដ៏ខ្លីនេះ ដោយនឹងធ្វើការសិក្សាបកស្រាយចំណុចមួយគឺ *ស្ថានភាពខុសប្លែកគ្នារវាងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង គ្រឹះស្ថានឧត្តមសិក្សាឯកជន* ។ វិស័យឯកជនបានចាប់ផ្តើមមាននៅពេលដែលមានកំណើនប្រជាជន និង តម្រូវការទីផ្សារកាន់តែខ្ពស់ ហើយដើម្បីបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជន ត្រូវទាមទារនូវការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និង កម្មវិធីសិក្សាសម្រាប់និស្សិតទៅតាមគោលនយោបាយរបស់ស្ថាប័នខ្លួនដាច់ដោយឡែកពីរដ្ឋ ដូច្នេះ វាមានភាពផ្សេងគ្នាខ្លះដូចជា ៖ ការរៀបចំកម្មវិធីសិក្សារបស់និស្សិត និង ការបង្រៀនរបស់គ្រូ គុណភាពរបស់និស្សិត នៅក្នុងគ្រឹះស្ថានរដ្ឋ និងមូលហេតុដែលនាំឲ្យនិស្សិតចង់រៀននៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ឬ ឯកជន ។

អត្ថបទនេះបានចាប់ផ្តើមធ្វើការស្រាវជ្រាវក្នុងរយៈពេលខ្លីមួយដែលចូលរួមដោយនិស្សិតបីរូប គឺ លោក រុន សម្បត្តិ កញ្ញា ហាក់ ស៊ីភិរ័តន៏ និង កញ្ញា ហេង ឈុនអឿន ។ ដឹកនាំបង្រៀន និង ផ្តល់យោបល់ដោយលោក គឹម សេតារា ។ អត្ថបទនេះ មិនមែនបង្ហាញពីបញ្ហាទូទៅនៃឧត្តមសិក្សាទាំងមូលទេ គឺវាគ្រាន់តែជាការសិក្សាស្រាវជ្រាវសាកល្បងអង្កេត ដោយជ្រើសយកមហាវិទ្យាល័យសង្គមវិទ្យា ប្រវត្តិវិទ្យា បុរាណវិទ្យា ស្ថាបត្យកម្ម និង សាលាកសិកម្មព្រែកលៀប ហើយយើងខ្ញុំបានទៅសម្ភាសផ្ទាល់ជាមួយសាស្ត្រាចារ្យ និង និស្សិតនៅមហាវិទ្យាល័យនីមួយៗ ដែលការសម្ភាសនេះគឺធ្វើតាមរបៀបពាក់កណ្តាលរៀបរយ (semi-structure interview) ដោយចូលរួមធ្វើការអង្កេតផ្ទាល់នៅនឹងទីកន្លែង តាមវិធីសាស្ត្រស្រាវជ្រាវបែបជាតិពន្ធុវិទ្យា ។ ក្រៅពីនេះ យើងខ្ញុំបានប្រមូលព័ត៌មានដែលទាក់ទងនឹងប្រធានបទមកជ្រើសរើសដកស្រង់គំនិតរបស់អ្នកនិពន្ធមុនៗ មកវិភាគ រួចធ្វើការរួមបញ្ចូលជាមួយនឹងអ្វីៗ ដែលយើងបានទទួលពីការស្រាវជ្រាវនៅពេលបច្ចុប្បន្ននេះ ។ ហើយភាគច្រើននៃព័ត៌មានក្នុងអត្ថបទនេះ គឺយើងសិក្សាផ្តោតសំខាន់ទៅលើតែមហាវិទ្យាល័យស្ថាបត្យកម្មប៉ុណ្ណោះ ដោយធ្វើការប្រៀបធៀបនឹងគ្រឹះស្ថានឯកជននរ័តុន ព្រោះវាមានមុខវិជ្ជាស្ថាបត្យកម្មដូចគ្នា ។

## ការរៀបចំកម្មវិធីសិក្សារបស់និស្សិត និង ការបង្រៀនរបស់គ្រូ

ការធ្វើកំណែទម្រង់កម្មវិធីសិក្សា និង ការបង្រៀននៃគ្រឹះស្ថានឧត្តមសិក្សា ត្រូវបានយកចិត្តទុកដាក់ដោយអាជ្ញាធរជាតិ និង គ្រឹះស្ថានរបស់ខ្លួនផ្ទាល់ ហើយដែលការរៀបចំឡើងវិញនេះគឺជាកត្តាសំខាន់សម្រាប់កែលម្អគុណភាពសិក្សារបស់និស្សិត និង ការបង្រៀនរបស់គ្រូ ។ កម្ពុជាស្ថិតក្នុងស្ថានភាពសេដ្ឋកិច្ចទីផ្សារសេរីដែលបើកចំហឲ្យមានគ្រឹះស្ថានឯកជន ដើម្បីដោះស្រាយបញ្ហាកំណើននៃយុវវ័យនៅថ្នាក់មធ្យមសិក្សា ធ្វើឲ្យសិស្សជាច្រើនបានចំណាយលុយចុះឈ្មោះចូលរៀនសម្រាប់ថ្នាក់ឧត្តមសិក្សារបស់ពួកគេ ។ ហើយនៅពេលនោះ បន្ទាប់ពីមានការប្រឡងប្រជែងទីផ្សារនៃប្រព័ន្ធអប់រំបែបនេះ ក៏បានធ្វើឲ្យគ្រឹះស្ថានឧត្តមសិក្សារដ្ឋត្រូវទាមទារឲ្យមានការជួយឧបត្ថម្ភខាងផ្នែក ថវិកា សម្ភារៈ និង បច្ចេកទេសពីអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដើម្បីពង្រីកនូវគុណភាពសិក្សារបស់គ្រឹះស្ថានខ្លួន ឲ្យមានលក្ខណៈស្របគ្នានឹងទីផ្សារការងារដោយធ្វើការកែទម្រង់នូវកម្មវិធីសិក្សារបស់និស្សិត និង ការបង្រៀន (Sloper 1999) ។ តាមរយៈការស្រាវជ្រាវរបស់យើងឃើញថា ភាគច្រើននៃគ្រឹះស្ថានឧត្តមសិក្សារដ្ឋពុំមានស្វ័យហិរញ្ញវត្ថុ ដើម្បីចាត់ចែងនូវដំណើរការទាំងនោះបានទេ គឺត្រូវពឹងផ្អែកទៅលើជំនួយរបស់អង្គការក្រៅរដ្ឋាភិបាលមួយចំនួនធំទាំងថវិកា សម្ភារៈ បច្ចេកទេស និង គ្រូបង្រៀន ដែលក្នុងនោះមានមហាវិទ្យាល័យសង្គមវិទ្យា និង ប្រវត្តិវិទ្យា ត្រូវបានជួយដោយអង្គការ ញូ ហ៊ុយម៉ានីធី (New Humanity) ឯមហាវិទ្យាល័យបុរាណវិទ្យា និង ស្ថាបត្យកម្ម មានអង្គការយូណេស្កូ ជាអ្នកជួយឧបត្ថម្ភគាំទ្រទាំងផ្នែកបច្ចេកទេសបណ្តុះបណ្តាល និង គ្រូបង្រៀន ។ ហើយកម្មវិធីសិក្សា និង ការរៀបចំបង្រៀនរបស់គ្រឹះស្ថានរដ្ឋមួយចំនួន គឺត្រូវបានគេរៀបចំឡើងឲ្យស្របគ្នាទៅនឹងតម្រូវការទីផ្សារការងារដោយមានការឯកភាពពីក្រសួង ឬ ម្ចាស់ជំនួយផងដែរ ។ ប៉ុន្តែតាមការបកស្រាយរបស់និស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានឲ្យដឹងថា ៖ ចំពោះកម្មវិធីសិក្សារបស់គ្រឹះស្ថានខ្លួន មានការផ្លាស់ប្តូរទៅតាមនាយកដែលឡើងកាន់អំណាច ហើយការប្តូរនេះគឺយោងទៅតាមនិន្នាការរបស់អ្នកគ្រប់គ្រងខ្លួនឯងផ្ទាល់ ។ ចំពោះគ្រូបង្រៀនក៏ដូចគ្នា គឺ

វិធីសាស្ត្រ ឬ ទ្រឹស្តីនៃការបង្រៀនខុសប្លែកទៅតាមប្រព័ន្ធផ្សេង។ គ្នា ដែលមានខ្មែរ បារាំង អាល្លឺម៉ង់ អូស្ត្រាលីជាដើម ដូច្នេះ វាជាការលំបាកមួយរបស់និស្សិតក្នុងការរៀនសូត្រ ដោយមិនដឹងថាទ្រឹស្តីប្រសើរមួយណាដែលអាចយកមកប្រើធ្វើជាមូលដ្ឋានគ្រឹះ សម្រាប់ការស្រាវជ្រាវឬការងារអនុវត្តរបស់ខ្លួនបានល្អទៅថ្ងៃមុខ។ រីឯបច្ចេកទេសក្នុងការរៀបចំកម្មវិធីបង្រៀនវិញ គឺវាអាស្រ័យទៅលើសមត្ថភាពរបស់គ្រូម្នាក់។ ជាអ្នកច្នៃដោយខ្លួនឯង រួចទើបដាក់ជូនទៅ យូណេស្កូ ត្រួតពិនិត្យដើម្បីធ្វើការសម្រេច ។ នេះបង្ហាញឲ្យឃើញថា ការចាត់ចែងកម្មវិធីសិក្សា គ្រូបង្រៀន និង ប្រព័ន្ធរៀបចំ នៅមានលក្ខណៈមិនច្បាស់លាស់ ដែលជាមូលហេតុធ្វើឲ្យប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាចុះខ្សោយទៅ។ ។

កម្មវិធីសិក្សានៅគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និង កម្មវិធីសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាឯកជន វាមានលក្ខណៈខុសគ្នា ឧទាហរណ៍ ដូចជានៅមហាវិទ្យាល័យស្ថាបត្យកម្ម រយៈពេលនៃការសិក្សា គឺ ៦ ឆ្នាំ ហើយរយៈពេលរៀនក្នុងមួយថ្ងៃ គឺ ៦ ម៉ោង ឬ ៨ ម៉ោង ចំណែកឯនៅគ្រឹះស្ថានឯកជននរ័តុន ដែលមានបង្រៀនទូវមុខវិជ្ជាស្ថាបត្យកម្មនេះ គឺ គេបង្រៀនតែរយៈពេល ៤ ឆ្នាំ ហើយកម្មវិធីសិក្សាក្នុងមួយថ្ងៃតែ ៤_៦ ម៉ោងប៉ុណ្ណោះ ដោយគេកាត់ចោលនូវមេរៀនមួយចំនួន ដើម្បីចំណាយថវិកា និង ពេលរៀនតិច ។ ចំណែកឯការទទួលស្គាល់នៃគ្រឹះស្ថានទាំងពីរមានដូចគ្នា គ្រាន់តែនៅតាមគ្រឹះស្ថានរដ្ឋច្រើនមានការជួយឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល ដោយបានផ្តល់ជាគ្រូបរទេស និង គ្រូដែលមានកម្រិតអនុបណ្ឌិត និង បណ្ឌិត ហើយគ្រូទាំងនោះ ច្រើនតែមានសមត្ថភាព និង មានតួនាទីធំនៅក្នុងស្ថាប័នណាមួយ ។ នៅត្រង់ចំណុចនេះ យើងឃើញយ៉ាងច្បាស់ថា ការរៀបចំកម្មវិធីសិក្សាពិតជាមានលក្ខណៈខុសប្លែកគ្នារវាងគ្រឹះស្ថានទាំងពីរ ហើយវាមានផលល្អ និង ផលអាក្រក់ជះត្រឡប់មកវិញផ្សេងពីគ្នាដែរ ។ បើយើងគិតទៅលើគុណភាពនៃកម្មវិធីសិក្សារបស់គ្រឹះស្ថានរដ្ឋ ទោះបីជារយៈពេលយូរឆ្នាំមែន ប៉ុន្តែវាស៊ីគ្នាទៅនឹងកម្រិតយល់ដឹងរបស់និស្សិតខ្មែរដែលពុំសូវមានការរីកចម្រើន រីឯគ្រឹះស្ថានឯកជនវាមានរយៈពេលសិក្សាខ្លី តែកម្មវិធី ឬ មេរៀនគេបានកាត់បន្ថយឲ្យរៀនតែ ៤ ឆ្នាំ ដើម្បីទុកឱកាសឲ្យនិស្សិតទៅរៀនដោយខ្លួនឯងនៅបណ្ណាល័យ ឬ នៅផ្ទះ ប៉ុន្តែនិស្សិតខ្មែរពុំមានទម្លាប់ស្រាវជ្រាវដោយខ្លួនឯង ដូច្នេះការដែលយកប្រព័ន្ធក្រេឌិត (Credit) សិក្សារយៈពេលសិក្សាខ្លីដូចប្រទេសជឿនលឿនមកអនុ_វត្តភ្លាម។ វាពុំអាចមានលទ្ធផលល្អប្រសើរប៉ុន្មានទេ ប៉ុន្តែនៅប្រទេសកម្ពុជា យើង អាចទទួលបានជោគជ័យលើបរិមាណធនធានមនុស្សច្រើនដោយសារការរៀបចំកម្មវិធីសិក្សា និង ការគ្រប់គ្រងមានភាពធូររលុង ជាកត្តាទាក់ទាញចំនួនសិស្សដែលបញ្ចប់មធ្យមសិក្សា ឲ្យមកចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សានៅតាមគ្រឹះស្ថានឯកជនបានច្រើន មូលហេតុទាំងអស់នេះហើយដែលរុញច្រានប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សាមិនអាចដើរឆ្ពោះទៅមុខដូចប្រទេសជឿនលឿននៅលើពិភពលោកបាន ហើយផលវិបាកវានឹងបង្ហាញឲ្យឃើញនៅពេលខាងមុខដោយចៀសមិនរួច ។

## គុណភាពរបស់និស្សិត

ជាទូទៅការវាយតម្លៃទៅលើគុណភាពនៃប្រព័ន្ធអប់រំ គឺគេវាយតម្លៃទៅលើអត្រានៃការឡើងថ្នាក់ អត្រាត្រួតថ្នាក់របស់និស្សិត ចំពោះការវាយតម្លៃបែបនេះ បើយោងទៅលើស្ថានការណ៍នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន គឺការវាយតម្លៃបែបនេះវាពុំមានលក្ខណៈសុក្រឹតទេ ព្រោះថាបើយើងក្រឡេកមើលទៅក្នុងការប្រឡងម្តង។ មិនថាការប្រឡងនោះមានរូបភាពបែបណានោះទេ គឺតែងតែមានអំពើពុករលួយ និងបក្សពួក ដូចជានិស្សិតម្នាក់លើកឡើងថា នៅក្នុងស្ថាប័នដែលគេបានរៀន គឺតែងមានអំពើស៊ីសំណូក ដូចជាអ្នកណាដែលប្រឡងធ្លាក់ គឺគេត្រូវយកលុយទៅឲ្យគ្រូ ឬ ដោយមធ្យោបាយផ្សេងទៀត ។ ចំពោះនិស្សិតមួយចំនួនធំ ទាំងនិស្សិតរៀននៅគ្រឹះស្ថានរដ្ឋ និងគ្រឹះស្ថានឯកជន គេលើកឡើងថា និស្សិតក្រោយពីបញ្ចប់ការសិក្សាគឺពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការស្វែងរកការងារធ្វើទេ ពីព្រោះដោយសារកម្មវិធីសិក្សារបស់មហាវិទ្យាល័យ គឺវាពុំទាន់មានលក្ខណៈច្បាស់លាស់ និងវាមានលក្ខណៈមិនគ្រប់គ្រាន់ ។

ហើយទន្ទឹមនឹងបញ្ហានេះផងដែរ មាននិស្សិតខ្លះ គេលើកឡើងថា នៅតាមមហាវិទ្យាល័យមិនផ្តល់ឱកាសឲ្យនិស្សិតស្វែងរកចំណេះដឹង ឬក៏បង្កើននូវសមត្ថភាពរបស់ខ្លួន តាមរយៈការធ្វើការងារក្រៅម៉ោងបានទេ ព្រោះមហាវិទ្យាល័យមានការតឹងរ៉ឹងចំពោះអវត្តមានខ្លាំងពេក ។ និស្សិតអាចមានសមត្ថភាពទៅបានវាមិនមែនអាស្រ័យទៅលើតែការអប់រំនៅតាមមហាវិទ្យាល័យប៉ុណ្ណោះទេ វាក៏អាស្រ័យទៅលើការទទួលការអប់រំក្រៅសាលា ឬ មហាវិទ្យាល័យដែរ ។ ប្រសិនបើយើងមិនបានចូលរួម ឬ ធ្វើការងារនៅក្នុងសង្គមទេនោះ គឺចំណេះរបស់យើងវាមិនកើនបានឡើយ ព្រោះថាការសិក្សាវាផ្សារភ្ជាប់ទៅនឹងការអនុវត្ត ទន្ទឹមនឹងនោះ យើងឃើញគ្រឹះស្ថានឯក_ជនរីកដុះដាលយ៉ាងច្រើន ដែលជាឱកាសទីផ្សារសេរីសម្រាប់គ្រូដែលមានសមត្ថភាពអាចទៅបង្រៀនម៉ោងបន្ថែម ក្រៅពីការងារនៅគ្រឹះស្ថានរដ្ឋ និង ដោយសារតែប្រាក់បៀវត្សរ៍តិចពេក គ្រូគាត់ត្រូវការយកពេលវេលាសម្រាប់ទៅបំពេញការងារក្រៅដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ចំពោះបញ្ហានេះ វាអាចចោទជាបញ្ហាខ្លះ។ ទៅលើគុណភាពនៃការសិក្សារបស់និស្សិត ពីព្រោះវាធ្វើឲ្យគ្រូទាំងនោះ គាត់ពុំបានបញ្ចេញនូវសមត្ថភាពដែលគាត់មាននោះឲ្យអស់ទេ ម្យ៉ាងទៀតគាត់គ្មានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាស្រាវជ្រាវបន្ថែមដើម្បីយកមកបង្រៀន គឺប្រការដែលសំខាន់គឺស្ថិតនៅលើប្រាក់បៀវត្សរ៍ជាធំ (sloper 1999) ។ បញ្ហាដែលចោទមួយទៀតទៅលើគុណភាពនៃការសិក្សារបស់និស្សិត គឺវាអាចស្ថិតនៅលើបុគ្គលិកលក្ខណៈរបស់និស្សិតនោះដោយខ្លួនឯងផ្ទាល់ ព្រោះថាចំពោះនិស្សិតខ្មែរភាគច្រើន គេពុំសូវទំលាប់ខ្លួនក្នុងការសិក្សាស្រាវជ្រាវដោយខ្លួនឯងទេ គេចាំតែទទួលនូវចំណេះដែលគ្រូបានបង្រៀននៅក្នុងថ្នាក់តែប៉ុណ្ណោះ ។

ដូច្នេះទាក់ទងនឹងបញ្ហាដែលបានរៀបរាប់ខាងលើនេះ វាធ្វើឲ្យគុណភាពនៃការសិក្សារបស់និស្សិតស្ថិតនៅក្នុងកម្រិតមួយដែលមិន

អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារបានឡើយ *នៅរៀងរាល់ឆ្នាំ យើងតែងតែឃើញមានចំនួននិស្សិតយ៉ាងច្រើនដែលបានរៀនចប់គ្មានការងារធ្វើ* ។ ដូច្នេះ យើងឃើញបច្ចុប្បន្នប្រព័ន្ធអប់រំមិនអាចបណ្តុះបណ្តាលឲ្យនិស្សិតមានសមត្ថភាពឡើយ ពោលគឺគ្រាន់តែបណ្តុះបណ្តាលឲ្យមានបរិមាណនិស្សិតច្រើនតែប៉ុណ្ណោះ ។

## មូលហេតុដែលនាំឲ្យនិស្សិតចង់រៀននៅគ្រឹះស្ថានរដ្ឋ

នៅពេលដែលបញ្ចប់ថ្នាក់មធ្យមសិក្សា និស្សិតត្រូវធ្វើការសម្រេចចិត្តជ្រើសរើសមុខវិជ្ជា ឬមហាវិទ្យាល័យណាមួយ ដែលខ្លួនចូលចិត្តដើម្បីរៀនបន្តយកថ្នាក់បរិញ្ញាប័ត្រ ។ សព្វថ្ងៃនេះស្រុកខ្មែរយើងមានជម្រើសពីរ គឺចំពោះសិស្សដែលមានលទ្ធភាពប្រឡងជាប់ ត្រូវរៀននៅគ្រឹះស្ថានរដ្ឋ រីឯអ្នកដែលធ្លាក់ពីការប្រឡង អាចមានសិទ្ធិបង់លុយដើម្បីចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យ ហើយក៏មានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ដូចគ្នា ដូច្នេះនិស្សិត ឬ ក្រុមគ្រួសាររបស់គេ ត្រូវមានមូលហេតុ និងជំនឿចិត្តរៀង ។ ខ្លួន ក្នុងការសម្រេចចិត្តនេះ ។

តាមទស្សនៈរបស់Mayor(1995)បានបង្ហាញពីគ្រឹះស្ថានឯកជននៅបណ្តាប្រទេសជឿនលឿននៅលើពិភពលោកមានលក្ខណៈទ្រង់ទ្រាយធំជាងគ្រឹះស្ថានរបស់រដ្ឋ ប៉ុន្តែបើផ្អែកលើពត៌មានដែលបានមកពីការចុះទៅអង្កេតផ្ទាល់នៅតាមមហាវិទ្យាល័យនីមួយៗ ឃើញថានិស្សិតនៅប្រទេសកម្ពុជាយើងច្រើនឲ្យតម្លៃ និង ផ្តល់អាទិភាពទៅស្ថាប័នរដ្ឋ ទាំងកម្មវិធីសិក្សារបស់និស្សិត ទាំងបច្ចេកទេស និង ធនធានគ្រូបង្រៀន គឺមានមូលដ្ឋានទ្រង់ទ្រាយធំជាងគ្រឹះស្ថានរបស់ឯកជន ។ ជាក់ស្តែងនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានឲ្យដឹងថា មហាវិទ្យាល័យរដ្ឋជាស្ថាប័នដែលមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល និង ប្រទេសដទៃទៀតជាលក្ខណៈអន្តរជាតិព្រោះនិស្សិតដែលបានអាហារូបករណ៍ថ្នាក់អនុបណ្ឌិត ឬ បណ្ឌិត ច្រើនតែចេញពីសាលារដ្ឋ ហើយម្យ៉ាងវិញទៀតប្រសិនបើមានការជួលគ្រូបរទេសល្អដែលមានសមត្ថភាពខ្ពស់ក្នុងការបង្រៀន ម្ចាស់ជំនួយ មិនដែលឲ្យទៅគ្រឹះស្ថានឯកជនទេ គឺគេសំដៅទៅជួយតែគ្រឹះស្ថានរដ្ឋ និស្សិតគេក៏ឲ្យតម្លៃទៅតាមហ្នឹងដែរ ព្រោះកេរ្តិ៍ឈ្មោះរបស់ស្ថាប័នរដ្ឋ អាចជាចំណែកមួយសម្រាប់ឱកាសរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សានៅមហាវិទ្យាល័យនេះ គឺជាមូលហេតុធំមួយដែលជំរុញឲ្យនិស្សិតចង់រៀននៅគ្រឹះស្ថានរដ្ឋ ទន្ទឹមនឹងនោះ យើងក៏ឃើញផងដែរថាមូលហេតុដែលនិស្សិតចូលរៀននៅគ្រឹះស្ថានរដ្ឋ គឺដោយសារកត្តាសេដ្ឋកិច្ចគ្រួសារនិស្សិតខ្លះគេពុំមានលទ្ធភាពបង់ប្រាក់ដើម្បីរៀននៅគ្រឹះស្ថានឯកជន ហើយកត្តាមួយទៀតគឺកត្តាគ្រួសារជាអ្នកណែនាំឲ្យចូលរៀន រីឯនិស្សិតខ្លះទៀត គឺចូលរៀនដោយការប្រឡងជាប់ដោយការចៃដន្យ ។ ចំណែកប្រព័ន្ធនៃការរៀបចំកម្មវិធីសិក្សារបស់គ្រឹះស្ថានឯកជន មានលក្ខណៈខុសពីរដ្ឋ គឺគេអនុវត្តតាមគំរូប្រទេសជឿនលឿននៅលើពិភពលោក ឧទាហរណ៍ការរៀនតាមបែបក្រេឌិតមកអនុវត្តក្នុងមហាវិទ្យាល័យរបស់ខ្លួន ដោយបង្រួមម៉ោងឲ្យនៅតែរយៈពេល ៤ ឆ្នាំ ។ ដូច្នេះឃើញថា និស្សិតអាចចំណេញពេលវេលា រៀនឆាប់ចប់ដើម្បីងាយរកការងារធ្វើ ឬ រកស៊ីចិញ្ចឹមជីវិត នេះជាមូលហេតុនាំឲ្យគេចង់ចូលរៀននៅគ្រឹះស្ថានឯកជន ។

## សេចក្តីសន្និដ្ឋាន

ជាសរុបមក គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺគ្រាន់ជាការស្វែងយល់ពីបញ្ហាខ្លះៗ ទៅលើស្ថានភាពនៃប្រព័ន្ធអប់រំខ្មែរសព្វថ្ងៃ ដែលបានផ្លាស់ប្តូរដោយបើកឲ្យមានគ្រឹះស្ថានឯកជនច្រើនដែលពាក់ព័ន្ធទៅនឹងបញ្ហាគុណភាពរបស់និស្សិតដែលរៀននៅថ្នាក់ឧត្តមសិក្សា ។ តាមការសិក្សារបស់យើងខ្ញុំ បានបង្ហាញឲ្យឃើញថាការធ្វើកំណែទម្រង់នេះវាមានចំណុចគ្រោះថ្នាក់ដល់សង្គម ដោយហេតុថា រដ្ឋាភិបាលយើងធ្វើការពុំមានលក្ខណៈច្បាស់លាស់ គឺអ្នកគ្រប់គ្រងគ្រឹះស្ថាននីមួយៗ មិនមែនជាមនុស្សដែលមានលទ្ធភាពគ្រប់គ្រងដឹកនាំ ដែលវាធ្វើឲ្យមានបញ្ហាពុករលួយរវាងនិស្សិត និងគ្រូ និង ជាពិសេសគោលនយោបាយស្រូបយកតែបរិមាណរបស់គ្រឹះស្ថានឯកជន មិនឃើញមានគុណភាពស្របនឹងទីផ្សារការងារដែលត្រូវការ ចំណុចនេះវានឹងនាំឲ្យមានការលំបាកខ្លាំងនៅថ្ងៃអនាគត ព្រោះចំនួននិស្សិតបញ្ចប់ពីមហាវិទ្យាល័យមានច្រើន ឯទីផ្សារដែលអាចទទួលពួកគេបានមានតិចតួច ឬ គ្មាន ដូច្នេះវិបត្តិនៃអ្នកអត់ការងារធ្វើកាន់តែមានច្រើនទៅៗ ដែលបញ្ហានេះ គឺជាបន្ទុកសង្គមដ៏ធ្ងន់សម្រាប់រាជរដ្ឋាភិបាលជាអ្នកដោះស្រាយ ។

គេអាចបកស្រាយបានថា ប្រព័ន្ធអប់រំកំពុងតែធ្វើការអភិវឌ្ឍនៅក្នុងប្រទេសខ្មែរ ប៉ុន្តែយើងខ្ញុំយល់ថា វាមានប្រសិទ្ធភាពចំពោះទីប្រជុំជនតែប៉ុណ្ណោះ គឺវាមិនអាចទៅបង្គ្រប់នឹងភាពខ្វះខាតនៅតំបន់ជនបទបានទេ ព្រោះអ្នកដែលរៀនចប់ចង់ធ្វើការងារនៅទីក្រុង ឬ ខេត្តធំៗ ទោះបីជាគ្មានការងារធ្វើ ពួកគេទាំងនោះមិនសុខចិត្តត្រឡប់ទៅស្រុកកំណើតវិញដែរ ជាក់ស្តែងតាមរយៈការចុះអង្កេតសួរផ្ទាល់ និង តាមរយៈបញ្ជីសំណួរដែលនិស្សិតនៅគ្រឹះស្ថានទាំងពីរបានបំពេញឃើញថា ចំនួននិស្សិតស្ទើរតែទាំងអស់បានសម្រេចចិត្តថា នឹងធ្វើការងារនៅទីក្រុងបន្ទាប់ពីរៀនចប់ វាជាបញ្ហាមួយដែលធ្វើឲ្យទីជនបទនៅតែខ្វះធនធានមនុស្សដដែល ហើយបញ្ហានេះ លោក sloper ក៏លើកយកមកនិយាយដែរ ។ វាបានសបញ្ជាក់ថា ប្រទេសមិនអាចរីកចម្រើនទៅមុខបានទេ ព្រោះថាវិស័យអប់រំមួយយើងឃើញថា ដំណើរការរបស់វាមិនស្របគ្នា ហើយវាត្រូវធ្វើឲ្យជះឥទ្ធិពលទៅលើគ្រប់វិស័យផ្សេងៗ ជាច្រើនទៀតឲ្យគាំងដំណើរការដែរ ដូចជាវិស័យសេដ្ឋកិច្ច នយោបាយ សង្គម សុខាភិបាល ចុះខ្សោយទៅតាមហ្នឹងដែរ ៕